# សេចក្ដីថ្លែងការណ៍រួម

## <u>សេចក្ដីព្រាងច្បាប់ស្ដីពី សណ្ដាប់ធ្នាប់សាធារណៈ ដែលរំលោភបំពានសិទ្ធិស្ត្រី</u>

*<u>ទម្លាក់ចោលសេចក្ដីព្រាងច្បាប់ បញ្ឈប់ការស្ដីបន្ទោសជនរងគ្រោះនៃអំពើហិង្សា</u>*

**រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០២០**

យើងខ្ញុំជាតំណាងអង្គការ និងសមាគមដែលកំពុងបំពេញបេសកកម្មដើម្បីលើកកម្ពស់សិទ្ធិស្ត្រី និងសមភាពយេនឌ័រនៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមសម្ដែងកង្វល់យ៉ាងខ្លាំងចំពោះមាត្រាជាច្រើនដែលមានចែងនៅក្នុងសេចក្ដីព្រាងច្បាប់ ស្ដីពីសណ្ដាប់ធ្នាប់សាធារណៈ (DLPO) ដែលរំលោភបំពានសិទ្ធិស្ត្រី។ យើងខ្ញុំក៏ចូលរួមគាំទ្រសំណើឱ្យទម្លាក់ចោលសេចក្ដីព្រាងច្បាប់នេះដែលបានលើកឡើងនៅក្នុង <u>សេចក្ដីថ្លែងការណ៍រួមរបស់សង្គមស៊ីវិល</u> ដែលបានផ្ញើជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ផងដែរ។

យើងខ្ញុំទទួលស្គាល់ និងកោតសរសើររាជរដ្ឋាភិបាលកម្ពុជា ដែលបានចាត់វិធានការវិជ្ជមានមួយចំនួនដើម្បីដោះស្រាយបញ្ហាវិសមភាពយេនឌ័រ តាមរយៈការផ្ដួចផ្ដើមគំនិតក្នុងការបង្កើតគោលនយោបាយជាច្រើន រួមមាន ផែនការសកម្មភាពជាតិ ស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដំណាក់កាលទីបី (NAPVAW III) ដែលនឹងដាក់ឱ្យប្រើប្រាស់នាពេលឆាប់ៗខាងមុខនេះ និងផែនការយុទ្ធសាស្ត្រលើកទីប្រាំ ដើម្បីសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីក្នុងប្រទេសកម្ពុជា (យុទ្ធសាស្ត្រនារីរតនៈទីV)។ ទោះជាយ៉ាងនេះក្ដី សេចក្ដីព្រាងច្បាប់នេះ បានធ្វើឱ្យពួកយើងមានការខ្វល់ខ្វាយយ៉ាងខ្លាំង ពីផលប៉ះពាល់នៃសេចក្ដីព្រាងច្បាប់នេះ ក្នុងការដាក់ទណ្ឌកម្មស្ត្រីចំពោះការស្លៀកពាក់ និងអាកប្បកិរិយា ដែលត្រូវបានបកស្រាយថាមានការបំពានលើក្រឹត្យក្រមសង្គមដែលមានលក្ខណៈរើសអើងទាក់ទងទៅនឹងការស្លៀកពាក់ និងការប្រព្រឹត្តរបស់ស្ត្រី។

យើងខ្ញុំសូមបញ្ជាក់ថា រាជរដ្ឋាភិបាលនឹងមិនអាចបំពេញនូវការប្ដេជ្ញាចិត្តរបស់ខ្លួន ក្នុងការសម្រេចឱ្យបានសមភាពយេនឌ័រនោះទេ ខណៈដែលរាជរដ្ឋាភិបាលនៅតែបន្តបន្ទាបតម្លៃស្ត្រី និងដាក់ទោសទណ្ឌមកលើស្ត្រី ព្រោះតែស្ត្រីមិនប្រតិបត្តិតាមក្រមសីលធម៌ និងស្តង់ដារនៃការស្លៀកពាក់ ដែលមានចរិតបែបអភិរក្សនិយម និងរឹតត្បឹត ក្រោមលេសចោទប្រកាន់ថាស្ត្រីហាក់កំពុងបង្កគ្រោះថ្នាក់ដល់សង្គម ។ ទន្ទឹមគ្នានេះ រាជរដ្ឋាភិបាលក៏មិនអាចដោះស្រាយបញ្ហាអំពើហិង្សាផ្លូវភេទ និងការបៀតបៀនផ្លូវភេទក្នុងសង្គមដែលកំពុងតែមានអត្រាដ៏ខ្ពស់បានដែរ បើសិនជារាជរដ្ឋាភិបាលមិនមានការលើកកម្ពស់សិទ្ធិអំណាចពេញលេញរបស់ស្ត្រីក្នុងការគ្រប់គ្រងលើរាងកាយ និងស្វ័យភាពផ្នែកផ្លូវភេទដោយស្ត្រីខ្លួនឯង មិនថ្កោលទោស និងផ្ដន្ទាទោសជនប្រព្រឹត្តអំពើហិង្សាផ្លូវភេទគ្រប់ទម្រង់នោះ។ អនុសាសន៍ខាងលើនេះ ក៏ត្រូវបានគណៈកម្មាធិការទទួលបន្ទុកអនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងលើស្ត្រី (គណៈកម្មាធិការ ស៊ីដ) លើកឡើងនៅក្នុងសេចក្ដីសង្កេតសន្និដ្ឋានឆ្នាំ ២០១៩ ជាពិសេសនៅក្នុងកថាខណ្ឌទី ១១(ង) ទី២៤(ក) និងទី ២៥។

សេចក្ដីព្រាងច្បាប់ដែលត្រូវបានស្នើឡើងនេះ អាចធ្វើឱ្យស្ត្រីបាត់បង់លទ្ធភាពទទួលបានសិទ្ធិរបស់ខ្លួនតាមរូបភាពពីរបែបសំខាន់ៗ ៖

**ទីមួយ** សេចក្ដីព្រាងច្បាប់នេះមានការរឹតត្បិតសិទ្ធិសេរីភាពរបស់ស្ត្រីក្នុងការសម្ដែងចេញ និងពង្រឹងផ្នត់គំនិតយេនឌ័រដែលផ្ដល់ផលអវិជ្ជមាន។ សេចក្ដីព្រាងច្បាប់នេះ បានបដិសេធសិទ្ធិរបស់ស្ត្រីក្នុងការជ្រើសរើស

សម្លៀកបំពាក់ផ្ទាល់ខ្លួន ដោយធ្វើការចោទប្រកាន់នូវជម្រើសនៃសម្លៀកបំពាក់របស់ពួកគេថា "សម្លៀកបំពាក់ដែលបញ្ចេញសាច់" មាន "ផលប៉ះពាល់អវិជ្ជមាន" ដល់ "ប្រពៃណី និងសេចក្តីថ្លៃថ្នូររបស់ជាតិ"។ ថ្វីត្បិតថាសេចក្តីព្រាងច្បាប់នេះក៏បានព្យាយាមដាក់កំហិតលើជម្រើសនៃការស្លៀកពាក់របស់បុរសផងដែរក្តី វាជាភស្តុតាងដែលបង្ហាញពីបរិបទច្បាប់ក្នុងសង្គមកម្ពុជា និងជាពិសេសផ្សាភ្ជាប់ទំនាក់ទំនងជាមួយស្ថានភាពគំរាមកំហែង និងការចាប់ខ្លួនស្ត្រីកម្ពុជា ទៅលើការស្លៀកសម្លៀកបំពាក់ដែលបើកបង្ហាញរាងកាយរបស់ពួកគេ នៅក្នុងពេលលក់ផលិតផលតាមអនឡាញនាពេលថ្មីៗនេះ ការណ៍នេះបានឆ្លុះបញ្ចាំងឱ្យឃើញថា ពង្រាងច្បាប់នេះកំណត់គោលដៅលើស្ត្រី ច្រើនជាងបុរស។ សកម្មភាពកាត់ទោសដោយផ្អែកលើការរើសអើងនេះ ក៏បង្ហាញឱ្យឃើញយ៉ាងច្បាស់នូវទង្វើរំលោភបំពានមកលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ស្ត្រី ដែលមានចែងក្នុងមាត្រា ៣១ និង៤៥ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និង មាត្រា ២ និងមាត្រា ៥ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (ស៊ីដ) ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។ សេចក្តីព្រាងច្បាប់នេះ នឹងធ្វើឱ្យឥរិយាបទភេទ ចាក់ឫសកាន់តែជ្រៅនៅក្នុងបទដ្ឋានគតិយុត្តិ ស្តីពីការស្លៀកពាក់ និងការប្រព្រឹត្តរបស់ស្ត្រី ហើយផ្តល់សិទ្ធិដល់អាជ្ញាធរក្នុងការធ្វើគោលនយោបាយដែលរំលោភបំពានលើរូបរាងកាយ និងជម្រើសរបស់ស្ត្រី និងពង្រឹងវប្បធម៌នៃការរើសអើងផ្អែកលើភេទកាន់តែទូលំទូលាយថែមទៀត។ ប្រហាក់ប្រហែលគ្នានេះដែរ សេចក្តីព្រាងច្បាប់នេះ ទំនងជាត្រូវបានយកមកប្រើដោយមិនស្មើភាពគ្នាប្រឆាំងនឹងសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា ជាពិសេសសិល្បករសម្តែង ដែលមានដូចជាអ្នករាំជាបុរសតុបតែងខ្លួនជានារី (ជ្រេកឃ្វីន ) អ្នករបាំសហសម័យ និងតារាបង្ហាញម៉ូត។

**ទីពីរ** សេចក្តីព្រាងច្បាប់នេះ មានការរើសអើងទៅលើក្រុមដែលប្រឈមមុខនឹងហានិភ័យខ្ពស់នៅក្នុងសង្គម ជាពិសេសគឺស្ត្រី។ សេចក្តីព្រាងច្បាប់នេះដាក់ទោសទណ្ឌចំពោះសកម្មភាពក្នុងគ្រួសារ សកម្មភាពផ្នែកសង្គម និងសេដ្ឋកិច្ចមួយចំនួន ដែលភាគច្រើននៃអ្នកទទួលបន្ទុកចម្បងនៃកិច្ចការទាំងនោះនៅក្នុងបរិបទប្រទេសកម្ពុជាគឺជាស្ត្រី។ កម្លាំងពលកម្មនៅក្នុងវិស័យក្រៅប្រព័ន្ធភាគច្រើន ត្រូវបានបង្កើតឡើងដោយស្ត្រី ដែលរួមមានស្ត្រីប្រកបរបរផ្លូវភេទ និងអ្នកលក់ដូរតាមចិញ្ចើមផ្លូវ ដែលវិជ្ជាជីវៈទាំងនេះ នឹងត្រូវហាមឃាត់ និងពិន័យ។ ថ្វីបើសេចក្តីព្រាងច្បាប់នេះមិនផ្តោតចំៗលើស្ត្រី និងក្មេងស្រីក៏ដោយ ក្នុងន័យនេះសេចក្តីព្រាងច្បាប់នេះនឹងផ្តល់ផលប៉ះពាល់ជាក់ស្តែង ដោយមិនស្មើភាពគ្នាមកលើស្ត្រីច្រើនជាងបុរស ចំពោះលទ្ធភាពក្នុងការទទួលបាន និងប្រើប្រាស់សិទ្ធិមនុស្សដោយពេញលេញ ដូចមានចែងក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ជាពិសេសគឺអនុសញ្ញាស៊ីដ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR) និងច្បាប់ស្តីពីការការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

បន្ថែមពីលើ<u>សេចក្តីថ្លែងការណ៍រួមដែលបានចុះហត្ថលេខាដោយអង្គការសង្គមស៊ីវិលចំនួន ៧៩ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០</u> កន្លងមកនោះ យើងខ្ញុំសូមលើកឡើងអំពីក្តីបារម្ភជាក់លាក់ដែលទាក់ទងទៅនឹងយេនឌ័រ លើសេចក្តីព្រាងច្បាប់នេះដូចតទៅ៖

**មាត្រា ១** បញ្ជាក់ថា ច្បាប់នេះមានគោលបំណង "ធានាការគ្រប់គ្រងណ្តាប់ធ្នាប់សាធារណៈ ឱ្យមានរបៀបរៀបរយ សោភ័ណភាព អនាម័យ បរិស្ថាន ភាពស្ងប់ស្ងាត់ សុវត្ថិភាពសង្គម ថែរក្សាប្រពៃណីជាតិ និងសេចក្តីថ្លៃថ្នូររបស់ពលរដ្ឋ"។ យើងមានការព្រួយបារម្ភយ៉ាងខ្លាំងថា ពង្រាងច្បាប់នេះនាំឱ្យមានការរឹតត្បិតលើសេរីភាព

របស់ស្ត្រី ដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យមិនច្បាស់លាស់ដូចជា ទៅលើពាក្យ "ប្រពៃណីជាតិ និង សេចក្តីថ្លៃថ្នូរ" "សោភ័ណភាព" "ភាពស្ងប់ស្ងាត់" និង"ស្ថេរភាពសង្គម" មិនមានលក្ខខណ្ឌរឹតត្បិតស្របច្បាប់ណាមួយចំពោះសិទ្ធិមនុស្សក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិទេ។

**មាត្រា ៩ និង ១១** មិនស្មើភាពគ្នាទៅលើអ្នកប្រកបរបរផ្លូវភេទ និងអ្នកធ្វើការក្នុងគ្រឹះស្ថានសេវាកំសាន្ត ព្រមទាំងកម្មករនិយោជិតក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាពិសេសអ្នកលក់ដូរតាមដងផ្លូវ។ មុខរបរទាំងនេះ ភាគច្រើនគឺជាមុខរបររបស់ស្ត្រី ដែលត្រូវប្រើប្រាស់ទីសាធារណៈដើម្បីរកចំណូល។ ការរឹតបន្តឹងដូចដែលបានចែងឡើងក្នុងសេចក្តីព្រាងច្បាប់នេះ នឹងរឹតបន្តឹងយ៉ាងធ្ងន់ធ្ងរមកលើសិទ្ធិប្រកបការងាររបស់ស្ត្រីទាំងនោះ។ បន្ថែមលើនេះទៀត សេចក្តីព្រាងច្បាប់នេះនឹងផ្តល់អំណាចដល់អាជ្ញាធរមូលដ្ឋានក្នុងការរឹបអូសជាបណ្តោះអាសន្ននូវសម្ភារៈ ឬភស្តុតាងពាក់ព័ន្ធជាមួយបទល្មើស ប្រសិនបើបុគ្គលល្មើសមិនអាចបង់ប្រាក់ពិន័យ ឬអវត្តមាន ឬមិនអាចកែតម្រូវបញ្ហាបាន។ មាត្រាទាំងនេះ ក៏ដាក់បន្ទុកក្នុងការរក្សាសណ្តាប់ធ្នាប់មកលើពលរដ្ឋជាបុគ្គលជំនួសឱ្យមានការទាមទារក្នុងការបំពេញការទទួលខុសត្រូវរបស់រដ្ឋាភិបាល ដោយផ្តល់ឱ្យបានគ្រប់គ្រាន់នូវសុវត្ថិភាព បង្គន់អនាម័យដែលមានគុណភាពល្អ ធុងសំរាម និងបុគ្គលិក/អ្នកជាប់កិច្ចសន្យាគ្រប់គ្រាន់ដើម្បីសម្អាតទីសាធារណៈ និងប្រមូលសំរាម។

**មាត្រា ១៦** មានអានុភាពបង្កគ្រោះថ្នាក់បន្ថែមទៀតដល់អ្នករងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ ដោយបង្កឱ្យកាន់តែលំបាកក្នុងការស្វែងរកជំនួយ ហើយមានទោសទៅវិញ។ បទបញ្ញត្តិនេះបានចែងចំពោះការប្រើពាក្យសម្តីឮ សំឡេងខ្លាំង ឬការស្រែកឡូឡា ថាជាបញ្ហាសណ្តាប់ធ្នាប់សាធារណៈ និងកំណត់និយមន័យ "ទីសាធារណៈ" យ៉ាងទូលាយដោយរួមបញ្ចូលទាំងផ្ទះឯកជនផងដែរ ប្រសិនបើសំឡេងនៅខាងក្នុងផ្ទះអាចឱ្យគេឮពីខាងក្រៅបាន។ ការចែងបែបនេះបង្កជាហានិភ័យ ដែលអាជ្ញាធរអាចចាត់ថ្នាក់សំឡេងច្រឡំចំពោះការស្រែករកជំនួយ ឬស្រែកតតាំងនឹងជនប្រព្រឹត្តបទល្មើស ថាជាបញ្ហាសណ្តាប់ធ្នាប់សាធារណៈ ជំនួសឱ្យជាអំពើហិង្សាក្នុងគ្រួសារដូចមានចែងនៅក្រោមច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ ការណ៍នេះក៏អាចបង្ករគ្រោះភ័យដល់ស្ត្រីដែលធ្លាប់ទទួលរងនូវអំពើហិង្សា ហើយស្វែងរកជំនួយពីព្រោះ ប៉ូលីសអាចលើកឡើងពីហេតុផលច្បាប់ក្នុងការដាក់ទោសពួកគេទៅវិញ ចំពោះការបំពានលើច្បាប់ស្តីពី សណ្តាប់ធ្នាប់សារធារណៈនេះ ដោយមិនមានការដោះស្រាយលើករណីអំពើហិង្សា ដែលក្រុមស្ត្រីកំពុងជួបប្រទះឡើយ។

**មាត្រា ២០** ហាមឃាត់ "ការចូលទៅក្នុងផ្ទះជនដទៃ អគារ ស្ថាប័នសាធារណៈ និងស្ថាប័នឯកជនដោយប្រើឧបករណ៍បិទបាំងមុខ ដែលមិនអាចកំណត់អត្តសញ្ញាណបាន។ ចំណុចនេះ មិនត្រឹមតែអាចបំពានសិទ្ធិស្ត្រីដែលពាក់ក្រណាត់រុំមុខដើម្បីឱ្យត្រូវតាមជំនឿសាសនារបស់ខ្លួនតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចបង្កហានិភ័យផ្នែកសុខភាពសាធារណៈបន្ថែមទៀត តាមរយៈការហាមឃាត់ការពាក់ម៉ាសនៅក្នុងអំឡុងពេលជំងឺកូវីដ១៩នេះផងដែរ។

**មាត្រា ២៥** មិនត្រឹមតែរើសអើងអ្នកមានពិការភាពផ្នែកសតិបញ្ញាតែប៉ុណ្ណោះទេ ប៉ុន្តែក៏មានផលប៉ះពាល់ដោយមិនស្មើភាពមកលើស្ត្រី ដោយនៅក្នុងប្រទេសកម្ពុជា ស្ត្រីជាអ្នកទទួលខុសត្រូវផ្តល់ការថែទាំចម្បងដល់អ្នក

មានពិការភាព តាមរយៈការទាមទារឱ្យពួកគេត្រូវរារាំងមិនឱ្យអ្នកមានពិការភាពផ្នែកសតិបញ្ញាអាចដើរហើរបានដោយសេរី។

**មាត្រា ២៩** អាចប៉ះពាល់ដល់ស្ត្រី និងកុមារដែលត្រូវរស់នៅក្នុងបរិវេណការដ្ឋានសំណង់ ប្រសិនបើច្បាប់ដាច់ដោយឡែកមួយទៀតស្តីពីការគ្រប់គ្រងសំណង់ ខកខានមិនបានពិចារណាឱ្យបានត្រឹមត្រូវ អំពីការផ្តល់លំនៅដ្ឋានចាំបាច់សម្រាប់ស្ត្រី និងកុមារនៅការដ្ឋានសំណង់។

**មាត្រា ៣៦** ហាមឃាត់បុរសដោះអាវក្នុងទីសាធារណៈ និងហាមឃាត់ស្ត្រីស្លៀកសម្លៀកបំពាក់ "ខើចលើខើចក្រោម" ឬ "ស្តើងអាចមើលឃើញ ឬបង្ហាញផ្នែកខ្លះនៃកេរ្តិ៍ភេទ" ។ បទបញ្ញត្តិនេះរំលោភលើសិទ្ធិសេរីភាពក្នុងការសម្តែងចេញរបស់ស្ត្រី ធ្វើឱ្យប៉ះពាល់ដល់ស្វ័យភាពផ្ទាល់ខ្លួន និងធ្វើឱ្យមានការរើសអើងប្រឆាំងនឹងស្ត្រីដែលបានប្រឈមនឹងផ្នត់គំនិតយេនឌ័រ និងបទដ្ឋានសង្គមបែបអវិជ្ជមានដែលចាក់ឫសជ្រៅក្នុងសង្គម។ រាជរដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចត្រូវគោរព ការពារ និងធានាសិទ្ធិបុគ្គលគ្រប់រូបទាំងអស់ក្នុងការស្តែងចេញនូវអត្តសញ្ញាណរបស់ខ្លួន និងចាំបាច់ត្រូវបង្កើតបរិយាកាសដែលជនគ្រប់រូបអាចធ្វើការជ្រើសរើសអំពីការស្លៀកពាក់របស់ខ្លួនដោយសេរី ដោយគ្មានការបង្ខិតបង្ខំ។ ការបកស្រាយរបស់រដ្ឋអំពីសាសនា វប្បធម៌ ឬប្រពៃណីពុំអាចបង្ហាញពីភាពត្រឹមត្រូវក្នុងការបង្កើតឱ្យមានវិធានការច្បាប់ស្តីពីការស្លៀកពាក់មកលើអ្នកដែលជ្រើសរើសយកការស្លៀកពាក់ខុសប្លែកពីជនដទៃនោះឡើយ មិនថានៅក្រៅប្រព័ន្ធអ៊ីនធឺណិត ឬនៅតាមអនឡាញក្តី។[1] ស្ត្រីនៅកម្ពុជាប្រឈមមុខនឹងការគម្រាមកំហែងជាញឹកញាប់ និងការដាក់ពន្ធនាគារដោយសារតែជម្រើសនៃសម្លៀកបំពាក់របស់ពួកគេ។ ឧទាហរណ៍ ជារឿយៗតែងមានការស្តីបន្ទោសមកលើអ្នករងគ្រោះពីអំពើបៀតបៀន និងអំពើរំលោភសេពសន្ថវៈថាបាន "ទាក់ទាញ" ជនប្រព្រឹត្ត តាមរយៈការស្លៀកពាក់ ឬទង្វើរបស់ខ្លួន ហើយមានការផ្តោតការយកចិត្តទុកដាក់តិចតួចលើការដាក់ទណ្ឌកម្មជនប្រព្រឹត្តអំពើបៀតបៀនផ្លូវភេទតាមដងផ្លូវ ឬអំពើហិង្សាផ្លូវភេទប្រឆាំងស្ត្រី និងក្មេងស្រី។ សេចក្តីព្រាងច្បាប់នេះអាចបង្កើតនូវទស្សនៈខុសឆ្គងស្តីពីបុព្វហេតុឫសគល់នៃអំពើហិង្សាប្រឆាំងស្ត្រី និងក្មេងស្រីនៅក្នុងប្រទេសកម្ពុជា ។

ជាងនេះទៅទៀត មាត្រា ៣៦ នេះគឺមិនចាំបាច់ទាល់តែសោះ ពីព្រោះក្រមព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា បានដាក់ទោស " ការបង្ហាញកេរ្តិ៍ភេទនៅក្នុងទីសាធារណៈ" រួចមកហើយ (នៅក្នុងមាត្រា ២៤៩)។ ជាចុងក្រោយ មាត្រា ៣៦ នេះមិនបានកំណត់លក្ខខណ្ឌនៃកម្មវត្ថុ នៅក្នុងសេចក្តីព្រាងនេះទេ ដែលអាចជាចន្លោះប្រហោងក្នុងការអនុវត្តដោយមិនស្មើភាពគ្នា និងនាំឱ្យមានអំពើពុករលួយក្នុងការអនុវត្តច្បាប់។

**មាត្រា ៣៧** រឹតត្បិតសេរីភាពក្នុងការសម្តែងចេញ ទាំងតាមប្រព័ន្ធអ៊ីនធឺណេត និងក្រៅប្រព័ន្ធអ៊ីនធឺណេត និងពង្រីកអំណាចរបស់អាជ្ញាធរក្នុងការគ្រប់គ្រងប្រព័ន្ធទំនាក់ទំនងសង្គមរបស់ស្ត្រី និងស្ត្រីអ្នកប្តូរភេទដែលអាជ្ញាធរបានផ្តន្ទាទោសរួចទៅហើយចំពោះការលក់ផលិតផលតាមអ៊ីនធឺណេត ដោយផ្អែកលើការចោទប្រកាន់ថាបានបង្ហាញភាពសិចស៊ីជ្រុលដែលអាចបង្កឱ្យមានការស្រើបស្រាលផ្លូវភេទ។

ជារួមនៃសេចក្តីថ្លែងការណ៍នេះ យើងខ្ញុំស្នើសូមយ៉ាងទទូចឱ្យរាជរដ្ឋាភិបាលកម្ពុជារក្សាកាតព្វកិច្ចរបស់រដ្ឋទៅតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងអស់ នៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ មាត្រា ៥ នៃអនុ

[1] Amnesty International, *'Women's right to choose their dress, free of coercion'* 4 March 2011, available online at: https://www.amnesty.nl/content/uploads/2017/02/womens_right_to_dress_boerkaverbod_3.pdf?x68187

សញ្ញាស៊ីដ បានទាមទារឱ្យប្រទេសកម្ពុជាត្រូវតែចាត់វិធានការសមស្របទាំងអស់ ដើម្បីកែសម្រួលទម្រង់អាកប្បកិរិយាផ្នែកសង្គម និងផ្នែកវប្បធម៌របស់បុរស និងស្ត្រីក្នុងបំណងសម្រេចឱ្យបាននូវការលុបបំបាត់បុរេនិច្ឆ័យ និងទំនៀមទម្លាប់ ព្រមទាំងការអនុវត្តទាំងអស់ដទៃទៀតដែលផ្អែកលើគំនិតប្រកាន់ភាពតូចទាបជាង ឬប្រកាន់ភាពខ្ពង់ខ្ពស់ជាងរបស់ភេទណាមួយ ឬការប្រកាន់តួនាទីតាមផ្នត់គំនិតចាស់គំរឹលសម្រាប់ស្ត្រី និងបុរស។ យើងខ្ញុំសូមអំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជាអនុវត្ត សេចក្តីសង្កេតសន្និដ្ឋានឆ្នាំ២០១៩ របស់គណៈកម្មាធិការស៊ីដ រួមមានវាក្យខណ្ឌ ១១(គ) ២៤(ក) និង២៥ ដែលទាមទារឱ្យរាជរដ្ឋាភិបាលត្រូវ "*វាយតម្លៃជាលក្ខណៈប្រព័ន្ធទៅលើផលប៉ះពាល់នៃវិធានការនានា ដែលបានដាក់ចេញ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាផ្អែកលើយេនឌ័រទៅស្ត្រី និងក្មេងស្រី និងបន្តស្វែងរក និងដាក់ចេញនូវវិធីសាស្ត្រថ្មីៗ ដើម្បីដោះស្រាយនូវឫសគល់អំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រី និងក្មេងស្រី*" បន្ថែមលើនេះទៀត នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការស៊ីដ ត្រង់កថាខណ្ឌ ៩(ខ) បានផ្តល់អនុសាសន៍មករាជរដ្ឋាភិបាលកម្ពុជាថា "*ត្រូវធ្វើការវាយតម្លៃប៉ាន់ប្រមាណផលប៉ះពាល់យេនឌ័រជាលក្ខណៈប្រព័ន្ធ នៅពេលអនុម័ត ឬធ្វើវិសោធនកម្មច្បាប់នានា និងធានាថាការធ្វើវិសោធនកម្មច្បាប់ទាំងនោះ នឹងជួយលើកកម្ពស់ និងការពារសិទ្ធិស្ត្រី* " ។ ខ្លឹមសារនៃសេចចក្តីព្រាងច្បាប់ស្តីពី សណ្តាប់ធ្នាប់សារធារណៈ បច្ចុប្បន្ននេះ បានបង្ហាញឱ្យឃើញថារាជរដ្ឋាភិបាលកម្ពុជា បរាជ័យក្នុងការវាយតម្លៃពីផលប៉ះពាល់អវិជ្ជមានដែលអាចមានមកលើស្ត្រី ហើយធ្វើឱ្យមានការថយចុះ និងប៉ះពាល់ធ្ងន់ធ្ងរចំពោះការប្រើប្រាស់សិទ្ធិស្ត្រី ដែលផ្ទុយទៅនឹងកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមអនុសញ្ញា ស៊ីដ។

**<u>យើងខ្ញុំសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាឱ្យទម្លាក់ចោលនូវសេចក្តីព្រាងច្បាប់ស្តីពី សណ្តាប់ធ្នាប់សាធារណៈ នេះទាំងស្រុង និងជាបន្ទាន់។ ផ្ទុយទៅវិញរាជរដ្ឋាភិបាលគួរតែចាត់ទុកជាអាទិភាពបន្ទាន់ដើម្បីដោះស្រាយរាល់ទម្រង់នៃការរើសអើងយេនឌ័រ រួមមានអំពើហិង្សាផ្អែកលើយេនឌ័រ និងការរើសអើងក្នុងប្រព័ន្ធអប់រំ ការចូលរួមផ្នែកសេដ្ឋកិច្ច សង្គម និងនយោបាយតាមរយៈ កំណែទម្រង់ច្បាប់ និងការផ្លាស់ប្តូរគោលនយោបាយ។</u>**

### សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់៖

១) អ្នកស្រី អេង ចាន់ឌី អ្នកសម្របសម្រួលបណ្តាញយេនឌ័រ និងអភិវឌ្ឍន៍ ០៩៥ ៧៩៧ ៩០៩
២) អ្នកស្រី ជឹម ចាន់នាង អគ្គលេខាធិការអង្គការ អិនជីអូ ស៊ី ដ ០១២ ៦៦៨ ៨៥៣
៣) កញ្ញា បុណ្យ រចនា នាយិការប្រតិបត្តិអង្គការក្លាហាន ០៨៩ ៤៧៦ ១៤៦

### សេចក្តីថ្លែងការណ៍រួមនេះគាំទ្រដោយ៖

១) អង្គការអាក់សិនអេតកម្ពុជា
២) អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
៣) ក្រុមការងារដើម្បីដោះស្រាយទំនាស់
៤) អង្គការលើកលែងទោសអន្តរជាតិ
៥) សមាគមអ្នកបម្រើការងារតាមផ្ទះ

៦) សមាគមគាំពារស្ត្រីងាយរងគ្រោះ
៧) អង្គការបន្ទាយស្រី
៨) អង្គការអភិវឌ្ឍន៍សំលេងសហគមន៍
៩) មជ្ឈមណ្ឌលកម្ពុជាដើម្បីព័ត៌មានឯករាជ្យ
១០) មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ
១១) អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា
១២) បណ្តាញយុវជនកម្ពុជា
១៣) អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ
១៤) សហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា
១៥) សហភាពការងារកម្ពុជា
១៦) ក្រុមអនាគតយុវជនកម្ពុជាអាស៊ាន
១៧) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
១៨) មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា
១៩) គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)
២០) ហ្វាន់ដាស៊ាន់ អាឡូឡា
២១) អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា
២២) អង្គការឃ្លាំមើលសិទ្ធិមនុស្ស
២៣) សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ
២៤) ទីភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីអន្តរជាតិ
២៥) សមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍
២៦) អង្គការ ក្លាហាន
២៧) ក្រុមសន្សំប្រាក់នារី
២៨) អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី
២៩) អង្គការការពារសិទ្ធិជនជាតិភាគតិច
៣០) ផ្លេនេត អង់ហ្វង់ ឌីវេឡុបមិន
៣១) អង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់)
៣២) សានរូមិនអាក់សិនណេតវើក
៣៣) អង្គការស្ត្រីតាអាង
៣៤) សមាគមន៍វេសអារីអារីរ៉ូកូតានីកេនី
៣៥) អង្គការនារីដើម្បីសន្តិភាព
៣៦) អង្គការចំរើនស្ត្រី